**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៩០៧ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការកំណត់កម្រៃឆ្លងកាត់ លើមុខទំនិញមួយចំនួនដែលស្ថិតក្រោមនីតិវិធីឆ្លងកាត់គយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឆ្លងកាត់គយ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់កម្រៃធ្វើកាត់គយ (Customs Transit Fee) លើមុខទំនិញមួយចំនួន ដែលត្រូវបានដឹកជញ្ជូននាំចូលក្រោមនីតិវិធីធ្វើកាត់គយ តាមបញ្ញត្តិប្រកាសស្ដីពីការធ្វើកាត់គយដូចយោងខាងលើ តាមរូបភាពដូចខាងក្រោម ៖

| | |
|---|---|
| - គោ ក្របី និងសេះរស់ | ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយក្បាល |
| - ជ្រូក ចៀម និងពពែរស់ | ៥.០០០ (ប្រាំពាន់) រៀល ក្នុងមួយក្បាល |
| - សត្វស្លាប (មាន់ ទា ...) | ៥០០ (ប្រាំរយ) រៀល ក្នុងមួយគីឡូក្រាម |
| - ផលិតផលជលផល | ៥០០ (ប្រាំរយ) រៀល ក្នុងមួយគីឡូក្រាម |

**ប្រការ ២.-**

កម្រៃធ្វើកាត់គយត្រូវប្រមូលនៅសាខា ឬទីស្នាក់ការគយនិងរដ្ឋាករនាំចូលពាក់ព័ន្ធ ដោយត្រូវចេញបង្កាន់ដៃទទួលប្រាក់ប្រភេទ គរ.IV និងបង់ចូលថវិកាជាតិត្រង់ខ្ទង់អនុគណនីលេខ 7102 ។

**ប្រការ ៣.-**

សាខាគយនិងរដ្ឋាករ ដែលគ្រប់គ្រងភូមិសាស្ត្រមាត់ច្រកនាំចេញទៅវិញត្រូវផ្ទៀងផ្ទាត់អនុលោមភាពនៃការបំពេញបែបបទគយ រួមទាំងការបំពេញកាតព្វកិច្ចបង់កម្រៃខាងលើនេះផងដែរ ។ ក្នុងករណីមានការខកខានបំពេញកាតព្វកិច្ចដូចរៀបរាប់ខាងលើនេះ ប្រធានសាខាគយនិងរដ្ឋាករពាក់ព័ន្ធមានសិទ្ធិកំណត់កម្រិតពិន័យនៅនឹងកន្លែងទាបបំផុតស្មើមួយដងនៃប្រាក់កម្រៃដែលត្រូវជាប់ ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៥
  "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ